**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កំណត់ហេតុ
## កិច្ចប្រជុំការងារបច្ចេកទេសប្រចាំសប្តាហ៍
## ថ្ងៃ ច័ន្ទ ទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ នៅសាលប្រជុំ អ.ជ.ប.ជ.អ

នៅវេលាម៉ោង ៩:០០ ព្រឹក ថ្ងៃច័ន្ទ ទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានរៀបចំកិច្ចប្រជុំការងារបច្ចេកទេសប្រចាំសប្តាហ៍ របស់ខ្លួនក្រោមការដឹកនាំកិច្ចប្រជុំដោយ **ឯកឧត្តមវេជ្ជបណ្ឌិត តែង គន្ធី** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការចូលរួមពីអគ្គលេខាធិការរង ប្រធាន និងអនុប្រធាន នាយកដ្ឋាន ក្រោមឱវាទអគ្គលេខាធិការដ្ឋាន។

**១. សមាសភាពចូលរួម៖**

សមាសភាពចូលរួមក្នុងកិច្ចប្រជុំថ្ងៃនេះមានអគ្គលេខាធិការ អគ្គលេខាធិការរង ប្រធាន-អនុប្រធាននាយកដ្ឋាន សរុបទាំងអស់ ចំនួន១៨ រូប (មានភ្ជាប់ជូនបញ្ជីវត្តមានចូលរួម)។

**២. អវត្តមាន៖**

១. លោកវេជ្ជ. ស៊ឹម គឹមសាន ( ច្បាប់)

២. លោកវេជ្ជ. លី ចាន់វ៉ារុធ ( ច្បាប់)

**៣. ប្រធានបទនៃកិច្ចប្រជុំ៖**

៣.១. របាយការណ៍សកម្មភាពសំរាប់សប្តាហ៍កន្លងមកនិងសប្តាហ៍បន្ទាប់របស់នាយកដ្ឋាននីមួយៗ

៣.២. ការណែនាំរបស់អគ្គលេខាធិការតាមនាយកដ្ឋាន

៣.៣. សំណូមពររួម និងផ្សេងៗ

## ៤. ដំណើរការ និងលទ្ធផលនៃការប្រជុំ៖

ជាកិច្ចចាប់ផ្តើមនៃអង្គប្រជុំ **ឯកឧត្តមវេជ្ជ. តែង គន្ធី** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានមតិស្វាគមន៍ចំពោះ ឯកឧត្តម អគ្គលេខាធិការរង លោក-លោកស្រី ប្រធាន និងអនុប្រធាននាយកដ្ឋានទាំងអស់ ដែលបានចូលរួមក្នុងកិច្ចប្រជុំនាព្រឹកនេះ ព្រមទាំងឯឧ. បានបន្តជាអនុសាសន៍ សំរាប់ការងារដែលត្រូវធ្វើឲ្យហើយ នៅក្នុងត្រីមាសទីមួយ គឺត្រូវធ្វើ mapping ឲ្យហើយសំរាប់ ៦ខេត្ត/ក្រុង គឺខេត្ត បាត់ដំបង, សៀមរាប, កំពង់ចាម, ព្រះសីហនុ, បន្ទាយមានជ័យ និងកណ្តាលរួមទាំងរាជធានី ។

ក្នុងការចុះធ្វើ គឺដឹកនាំដោយអគ្គលេខាធិការរងទាំងបី ដោយចែងចេញជាបីក្រុម ដែលក្រុមនីមួយៗដឹកនាំ ដោយអគ្គរងមួយរូប ក្នុងនោះដែរ ប្រធាននាយកដ្ឋានជាអ្នកទទួលខុសត្រូវលើការចាត់ឈ្មោះមន្ត្រីចុះបេសកកម្ម និង លោកវេជ្ជ. រស់ សីលវ៉ាត់ យកករណីនៅភូមិរកាបង្កើតជាសំណួរដែលត្រូវដាក់បញ្ចូលទៅក្នុងបញ្ជីសំណួររួមមួយ (ដែលរៀបចំដោយឯឧ. ហោ ប៊ុនឡេង)។ ចំណែកនាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុ ត្រូវពិនិត្យមើល និងរៀបចំ ថវិកា មធ្យោបាយ និងពន្យល់ប្រាប់ពីបែបបទ លក្ខ័ណចុះបេសកកម្ម និងការធ្វើរបាយការណ៍ ។

ក្នុងឱកាសនោះដែរ លោកអគ្គរង រស់ សីលវ៉ាត់ បានមានសំណួរសួរថា តើការងារនេះវាអាចជាន់គ្នាជាមួយ នាយកដ្ឋាន M&E ដែរទេ?

ជាចម្លើយឯឧ.អគ្គលេខាធិការបានប្រាប់អង្គប្រជុំពីគោលបំណងរួមនៃការចុះបេសកកម្ម គឺកែសំរួលទស្សនៈ ការចុះបេសកកម្មតាមការបែងចែកថវិកាជាតិ ទៅជាការចុះបេសកកម្មតាមតម្រូវការរបស់ស្ថាប័នវិញ ដូចជាព្រឹត្តិ ការណ៍នៅខេត្តបាត់ដំបង ត្រូវប្រមូលព័ត៌មានសម្រាប់ប្រើនៅថ្ងៃនេះ និងសំរាប់ថ្ងៃក្រោយ។

ជាបន្ត ឯឧ.អគ្គលេខាធិការ បានបញ្ជាក់បន្ថែមថា មុនពេលចុះបេសកកម្មត្រូវផ្តល់ដំណឹងដល់គណៈកម្មាធិការ អេដស៍ខេត្ត/ក្រុង និងCC ទៅឲ្យលេខាធិការដ្ឋានអេដស៍ នៅកន្លែងដែលត្រូវចុះ ឲ្យបានដឹងជាមុន ធ្វើយ៉ាងនេះក៏ដើម្បី លើកដម្កើនកិត្តិយសរបស់យើងដែរ ។ បែបបទនៃការជូនដំណឹងអាចតាម E-mail ឬផ្ញើរជាលិខិតផ្ទាល់ ។ ក្នុងការងារនេះប្រគល់ឲ្យប្រធានក្រុមបេសកកម្មទទួលខុសត្រូវរាល់ភាពបត់បែន ដោយមាន៖

១. ចុះដាក់ស្តែង

២.យកបានព័ត៌មានត្រឹមត្រូវដែលបានទទួលពីមូលដ្ឋាន

៣. ពិភាក្សាជាមួយគណៈកម្មាធិការអេដស៍ខេត្ត/ក្រុង

មុនពេលត្រឡប់មកវិញ ត្រូវជ្រើសរើសពេលសំរាប់ជួបជាមួយគណៈកម្មាធិការអេដស៍ខេត្ត/ក្រុង ទោះបីជា គណៈកម្មាធិការអេដស៍ខេត្ត/ក្រុង ឲ្យជួបជាមួយអ្នកណាក៏ដោយ (លេខាធិការដ្ឋានអេដស៍.......... ) របាយការណ៍ តាមទូរស័ព្ទឈប់យកជាផ្លូវការហើយ។

លោកវេជ្ជ. រស់ សីលវ៉ាត់ បានជម្រាបបន្ថែមថា វាជាការល្អដែលយើងមានទិន្នន័យរួម តែសូមឲ្យមានការ Update Data នេះឲ្យបានជាប្រចាំរៀងរាល់ខែ និងត្រីមាស ដោយមានការចុះហត្ថលេខាបានត្រឹមត្រូវ ហើយផ្ញើទិន្នន័យនេះដល់មន្ត្រីអាជ្ញាធរយើងឲ្យបានគ្រប់ៗគ្នាដើម្បីឲ្យការផ្សព្វផ្សាយចេញទៅក្រៅដូចគ្នា ចៀសវាងការនិយាយចេញផ្សេងៗពីគ្នា ហើយម៉្យាងទៀតវាជាការល្អដែលថាយើងចុះទៅជាដំបូងយើងទៅជួប ហើយប្រមូលព័ត៌មាន និងចុងក្រោយទៅជួប ជាមួយគណៈកម្មាធិការអេដស៍ខេត្ត/ក្រុងថា តើការជួបនេះយើងមានគោលដំហរ/ គោលការណ៍អ្វីសម្រាប់ជួប ជាមួយគណៈកម្មាធិការអេដស៍ខេត្ត/ក្រុង ? បើយើងមានគោលការណ៍រួមពីរទៅបីចំនុចវាជាការល្អសំរាប់ជួបគាត់ ។

ជាចម្លើយ ឯឧ.អគ្គលេខាធិការបានមានប្រសាសន៍ថា នាយកដ្ឋាន M&E ជាកន្លែង Stock Data ប្រមូល Data និងផលិតជាផ្លូវការ ។ មួយទៀតត្រូវពិនិត្យមើលរាល់ចំនុចខ្វះខាត ដើម្បីជាសំនួរពិនិត្យឡើងវិញដោយសួរថាតើការងារសព្វថ្ងៃមានការលំបាក និងការងាយស្រួលយ៉ាងដូចម្តេចដែរ? ចុះសំរាប់ឃុំសង្កាត់ តើវាយ៉ាងណាដែរ, សំរាប់ព័ត៌មានដែលខ្ញុំទទួលបានពី NCHADS និងទិន្នន័យដែលឯកឧត្តមមាន មានកន្លែងខុសគ្នា តើឯឧ.គិតដូចម្តេចដែរ? ឧទាហរណ៍មួយទៀតថាឆ្នាំដែលបើកទៅអ្នកជម្ងឺមិនទទួលបានតើវាយ៉ាងដូចម្តេចដែរ។ ម្យ៉ាងទៀតយើងមានគោលការណ៍ណែនាំ៦ចំនុចនោះវាជាគោលការណ៍គ្រឹះ ជាទុនសំរាប់យកទៅពិភាក្សាវាអាចជាការគ្រប់គ្រាន់ហើយដែរ។

ឯឧ.ឈឹម ឃិនដារ៉េត បានឯកភាព លើការយកគោលការណ៍ ៧ចំនុចមកអនុវត្តដោយគ្រាន់តែយកចំនុចនីមួយៗ មកលំអិត ថាតើយើងត្រូវការអ្វីជាក់លាក់តែប៉ុណ្ណោះ។

ក្នុងនោះឯឧ.អគ្គលេខាធិការបានបញ្ជាក់សូមឲ្យ ឯឧ. ហោ ប៊ុនឡេង ជួយយ៉ាងរៀបចំបញ្ជីសំណួរ ឲ្យបានចប់ក្រោយបុណ្យចូលឆ្នាំចិន ដើម្បីយកមកប្រើប្រាស់។

ឯឧ.អគ្គលេខាធិការបានលើកឡើងផងដែរសំរាប់ការឃើត និងខ្វះព័ត៌មានសំរាប់ដាក់ចូលតាម Web-site និងជាទ្រឹស្តីសំរាប់ ឯឧ. ត្រូវពន្យល់ឲ្យបានយល់ច្បាស់ ហើយលើកទឹកចិត្តឲ្យធ្វើ យើងជាអ្នកមើលពីក្រោយ ឬជាអ្នកអភិបាល ជាបន្តយើងព្រលែងឲ្យធ្វើបន្តិចម្តងៗ។

លោកវេជ្ជ. រស់ សីលវ៉ាត់ អគ្គលេខាធិការរង បានលើកថា គួរតែបង្កើតឲ្យមានToR សំរាប់អ្នកស្ម័គ្រចិត្ត ដោយគិតថាការមកធ្វើការនេះបានទទួលចំណេះដឹងអ្វីទៅវិញខ្លះ ដូចជា Advocacy Develop plan Management ..... អាចបង្ហោះតាម Web-site ។

សំរាប់អ្នកស្ម័គ្រចិត្ត ឯឧ.អគ្គលេខាធិការ បានរៀបចំឲ្យមានការជួបជាមួយឯឧ. ជាទៀងទាត់ជារៀងរាល់ខែ បើមានចម្ងល់អ្វីអាចសួរបានទាំងអស់ និងរៀបចំឲ្យតាមនាយកដ្ឋានមានបទបង្ហាញ និងបង្រៀនដល់អ្នកស្ម័គ្រចិត្តទាំងនោះ ។

ជាចុងក្រោយ ឯឧ.អគ្គលេខាធិការ បានអគុណចំពោះការដឹកនាំការងារកន្លងមក និងសូមជូនពរឲ្យមានសុខភាពល្អសំរេចបានរាល់ភារៈកិច្ចក្នុងឆ្នាំថ្មី ។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង ១០:០០ នាទីព្រឹក ថ្ងៃ ខែ ឆ្នាំ ដដែល ប្រកបដោយបរិយាកាសរីករាយ និងស្និទ្ធស្នាល ជាទីបំផុត។

ថ្ងៃទី ខែកុម្ភៈ ឆ្នាំ២០១៥

| | | |
|---|---|---|
| បានឃើញ និងឯកភាព | បានពិនិត្យ និងកែសម្រួល | របាយការណ៍រៀបចំដោយ |
| អគ្គលេខាធិការ | ប្រធាននាយកដ្ឋាន | |
| **ឯកឧត្តមវេជ្ជ. តែង គន្ធី** | **លោកស្រីវេជ្ជ. ងិន លីណា** | **ឱសថ. ចេង ថា** |